# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៩ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍ ដែលសរសេរកាត់ថា **គ.ជ.អ.ទ.** ដើម្បីសម្រួលការផ្ទេរម្លាស់ទីអ្នកជំនាញទេសចរណ៍ ក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងជំរុញការផ្លាស់ប្តូរ ការអនុវត្តល្អៗ ក្នុងការកសាងសមត្ថភាពអ្នកជំនាញទេសចរណ៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅក្នុងប្រទេសជាសមាជិកអាស៊ានដទៃទៀត។

## ជំពូកទី២
## សមាសភាព

**មាត្រា ២.-**

សមាសភាព **គ.ជ.អ.ធ.** មានដូចខាងក្រោម៖

| | |
|---|---|
| ១. រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០១ រូប អនុប្រធាន |
| ៣. រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | ០១ រូប សមាជិក |
| ៤. រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ០១ រូប សមាជិក |
| ៥. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ០១ រូប សមាជិក |
| ៦. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ០១ រូប សមាជិក |
| ៧. តំណាងក្រសួងមហាផ្ទៃផ្នែកនគរបាលជាតិ | ០១ រូប សមាជិក |
| ៨. តំណាងគណៈកម្មាធិការជាតិបណ្តុះបណ្តាល | ០១ រូប សមាជិក |
| ៩. តំណាងគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | ០១ រូប សមាជិក |
| ១០. តំណាងសមាគមឧស្សាហកម្មទេសចរណ៍ | មួយចំនួន សមាជិក |
| ១១. តំណាងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍ | មួយចំនួន សមាជិក។ |

សមាសភាពជាក់ស្តែងរបស់ **គ.ជ.អ.ធ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា ៣.-**

**គ.ជ.អ.ធ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម ៖

-បញ្ជ្រាបការយល់ដឹង និងការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងកិច្ចព្រមព្រៀងទទួលស្គាល់គ្នា ទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន ព្រមទាំងផ្សព្វផ្សាយដំណឹង អំពីការងារលើប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន

-ពិនិត្យ តាមដាន និងធ្វើបច្ចុប្បន្នភាពលើស្តង់ដារសមត្ថភាព ស្តង់ដារជំនាញ កម្មវិធីបណ្តុះបណ្តាលរួមនិងនិយាមផ្សេងៗទៀត ដែលត្រូវយកទៅប្រើប្រាស់ជាមូលដ្ឋាន សម្រាប់ការបណ្តុះបណ្តាល និងសម្រាប់ការវាយតម្លៃលើគុណវុឌ្ឍិ សមត្ថភាពអ្នកជំនាញទេសចរណ៍អាស៊ាន តាមមុខជំនាញទេសចរណ៍ ដែលត្រូវបានទទួលស្គាល់ជារួមក្នុងក្របខ័ណ្ឌអាស៊ាន ដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

-វាយតម្លៃលើគុណវុឌ្ឍិ និងសមត្ថភាពអ្នកជំនាញទេសចរណ៍ ដូចបានកំណត់ក្នុងស្តង់ដារសមត្ថភាពរួមរបស់អាស៊ាន សម្រាប់អ្នកជំនាញទេសចរណ៍ កម្មវិធីសិក្សារួមរបស់អាស៊ាន សម្រាប់អ្នកជំនាញទេសចរណ៍

-ពិនិត្យនិងតាមដានការប្រតិបត្តិរបស់អ្នកជំនាញទេសចរណ៍ ក្រោយពេលទទួលបានវិញ្ញាបនបត្របញ្ជាក់សមត្ថភាពវិជ្ជាជីវៈទេសចរណ៍ ពីគណៈកម្មាធិការជាតិបណ្តុះបណ្តាល

-សម្រួលការផ្លាស់ប្តូរព័ត៌មានទាក់ទងនឹងនីតិវិធីវាយតម្លៃ លក្ខណវិនិច្ឆ័យ និងប្រព័ន្ធផ្សព្វផ្សាយកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន

-ជូនដំណឹងដល់គណៈកម្មាធិការត្រួតពិនិត្យ អ្នកជំនាញទេសចរណ៍របស់អាស៊ាន ក្នុងករណីដែលអ្នកជំនាញទេសចរណ៍អាស៊ាន ដែលប្រកបអាជីពក្នុងព្រះរាជាណាចក្រកម្ពុជា លែងមានគុណវុឌ្ឍិក្នុងការផ្តល់សេវារបស់ខ្លួន ឬក្នុងករណីដែលអ្នកជំនាញទេសចរណ៍ បានរំលោភលើស្តង់ដារបច្ចេកទេសវិជ្ជាជីវៈ ឬក្រមសីលធម៌វិជ្ជាជីវៈ

-លើកសំណើជូនគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីដកហូតវិញ្ញាបនបត្រទទួលស្គាល់ ពីអ្នកជំនាញទេសចរណ៍ណាដែលលែងមានគុណវុឌ្ឍិ ក្នុងការផ្តល់សេវារបស់ខ្លួន ឬពីអ្នកជំនាញទេសចរណ៍ណាដែលរំលោភស្តង់ដារបច្ចេកទេសវិជ្ជាជីវៈ ឬក្រមសីលធម៌វិជ្ជាជីវៈ

-រៀបចំ និងពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងយន្តការសំខាន់ៗ ដើម្បីសម្រួលការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន

-ធ្វើសហការជាមួយក្រសួង ស្ថាប័ន ផ្នែកឯកជន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីសម្របសម្រួលការងារខាងលើ ឲ្យមានប្រសិទ្ធភាព

-បំពេញការងារផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ គ.ជ.អ.ទ.

**មាត្រា ៤.-**

**គ.ជ.អ.ទ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា ៥.-**

**គ.ជ.អ.ទ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជន ឲ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

**មាត្រា ៦.-**

បែបបទនិងនីតិវិធីអនុវត្តការងាររបស់ **គ.ជ.អ.ទ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងរបស់ **គ.ជ.អ.ទ.**។

**មាត្រា ៧.-**

**គ.ជ.អ.ទ.** អាចបង្កើតក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន។ តួនាទី និងភារកិច្ចក្រុមការងារជំនាញនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ជ.អ.ទ.**។

**មាត្រា ៨.-**

**គ.ជ.អ.ទ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួន តាមការចាំបាច់។

**មាត្រា ៩.-**

**គ.ជ.អ.ទ.** មានលេខាធិការដ្ឋានមួយនៅក្រសួងទេសចរណ៍ ជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន **គ.ជ.អ.ទ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ដែលជាប្រធាន **គ.ជ.អ.ទ.**។

**មាត្រា ១០.-**

**គ.ជ.អ.ទ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥
## ប្រភពធនធាន

**មាត្រា ១១.-**

**គ.ជ.អ.ឆ.** មានប្រភពធនធានផ្គត់ផ្គង់ដោយកញ្ចប់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងទេសចរណ៍ និងមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ ព្រមទាំងប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់បំពេញការងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ